# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ១៥/អនក្រ.បក
### ស្តីពីការបង្កើតគណកម្មការតាមដានដំណើរការ
### បែងចែកជំនួយសំរាប់ការងារសង្គមកិច្ច

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥/អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតប្រព័ន្ធជាតិសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ
- ផ្អែកលើការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

មាត្រា ១ .- បង្កើតគណកម្មការតាមដានដំណើរការបែងចែកជំនួយ ដែលបានមកពីប្រទេសនិងស្ថាប័នអន្តរជាតិនានា សំរាប់ការងារសង្គមកិច្ច ។

មាត្រា ២ .- គណៈកម្មការនេះ មានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រីក្រសួងផែនការ ជាប្រធាន

២- ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធាន

៣- ឯកឧត្តម **ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

៤- ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិក

៥- ឯកឧត្តម នឹម ថុន រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាសមាជិក

៦- ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋលេខាធិការក្រសួងសុខាភិបាល ជាសមាជិក

៧- លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋលេខាធិការក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ជាសមាជិក

៨- ឯកឧត្តម លី ធុច រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក

៩- ឯកឧត្តម ចាន់ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

មាត្រា ៣ ._ គណៈកម្មការខាងលើមានភារកិច្ចដូចខាងក្រោម :

- តាមដានរាល់សកម្មភាពបែងចែកជំនួយ របស់ប្រទេសនិងស្ថាប័នអន្តរជាតិ ម្ចាស់អំណោយទាន សំរាប់ការងារសង្គមកិច្ចក្នុងគោលបំណងធានាអោយបាននូវការបែងចែក អោយចំគោលដៅ និងការប្រើប្រាស់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ដើម្បីបង្កើននូវជំនឿជាក់ពីប្រទេសផ្តល់ជំនួយ
- វិភាគអំពីសមាមាត្រនៃការបែងចែកអោយបានសមស្របតាមទំហំការងារភារកិច្ច
- ប្រៀបធៀបសមាមាត្រ នៃការចំណាយរវាងផ្នែកសេដ្ឋកិច្ច យោធា នគរបាល និងការចំណាយផ្នែកសង្គមកិច្ច លើផ្នែកផ្សេងៗទៀតនៃជីវភាពជាតិសំដៅអោយមានការចំណាយយ៉ាងសមស្រប ទៅលើផ្នែកសង្គមកិច្ច
- ចូលរួមប្រជុំការងារអោយបានសកម្មតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ សំដៅរកគន្លឹះប្រសិទ្ធភាពទប់ស្កាត់រាល់ភាពអសកម្ម ក្នុងការបែងចែក
- តាមដានការអភិវឌ្ឍន៍នៃការចំណាយផ្នែកសង្គមកិច្ច
- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់គណៈកម្មការជូននាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលតាមកាលបរិច្ឆេទ ដែលបានកំណត់ក្នុងរបាយការណ៍ ។

មាត្រា ៤ ._ គណៈកម្មការតាមដានដំណើរការបែងចែកជំនួយ សំរាប់ការងារសង្គមកិច្ច មានក្រុមការងារអន្តរក្រសួងមួយ ដែលមានសមាសភាពចូលរួមពីអ្នកបច្ចេកទេសមកពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធខាង

លើជាជំនួយការខាងផ្នែកបច្ចេកទេសដោយធ្វើសហការយ៉ាងជិតស្និតជាមួយ គណៈកម្មការគ្រប់គ្រងវិនិយោគសាធារណៈ ដែលបានបង្កើតដោយអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨ ស្ដីពីការបង្កើតប្រព័ន្ធជាតិសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ ។

មាត្រា ៥ ._ គណកម្មការតាមដានដំណើរការបែងចែកជំនួយ សំរាប់ការងារសង្គមកិច្ច មានលេខាធិការដ្ឋានមួយដែលមានទីតាំងនៅក្រសួងផែនការ សំរាប់ជាជំនួយការក្នុងការងាររដ្ឋបាលប្រចាំ ។

មាត្រា ៦ ._ គណកម្មការនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័ន ឬមន្ត្រីជំនាញ ដែលមានការពាក់ព័ន្ធមករួមប្រជុំតាមការជាក់ស្ដែង ។

មាត្រា ៧ ._ គណកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការក្នុងកិច្ចដំណើរការរបស់ខ្លួន ។

មាត្រា ៨ ._ គណកម្មការតាមដានដំណើរការបែងចែកជំនួយសំរាប់ការងារសង្គមកិច្ច មានថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងផែនការ ។

មាត្រា ៩ ._ អនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតគណកម្មការតាមដាន ដំណើរការបែងចែកជំនួយសំរាប់ការងារសង្គមកិច្ច ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០._ អនុក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

មាត្រា ១១._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធ និងលោកជំទាវ ឯកឧត្ដម ដែលមាននាម ចែងក្នុងមាត្រា ២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងផែនការ

ហត្ថលេខា

**ឆាយ ថន**

★★★